# កម្មវិធី GREEN Mekong

## សមធម៌និងការពង្រឹងបណ្តាញនៅមូលដ្ឋាន ក្នុងតំបន់មេគង្គ

**សាវតា** ព្រៃឈើនៅតំបន់ទំនាបទន្លេមេគង្គបានគ្របដណ្តប់ស្ទើរតែពាក់កណ្តាលនៃតំបន់ទន្លេមេគង្គទាំងមូល ហើយបានផ្តល់នូវផលប្រយោជន៍យ៉ាងសំខាន់ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថានដល់ប្រជាសហគមន៍ដែលរស់នៅដោយពឹងអាស្រ័យលើព្រៃឈើ។ បច្ចុប្បន្ន ធនធានព្រៃឈើទាំងនេះកំពុងទទួលការគំរាមគំហែងពីការកាប់ទន្ទ្រានដីព្រៃក្នុងគោលបំណងប្រើប្រាស់ផ្សេងៗដូចជា ការធ្វើអាជីវកម្មព្រៃឈើ និងការបរបាញ់សត្វ ដោយគ្មាននិរន្តភាព ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តទ្រង់ទ្រាយធំ ការដុតបំផ្លាញព្រៃឈើ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ កិច្ចការពារព្រៃឈើបានទទួលនូវការយកចិត្តទុកដាក់ជាខ្លាំងជាសកល ដោយសារតែវាជាវិធីសាស្ត្ររយៈពេលវែងមួយ ដែលមាន មានប្រសិទ្ធិភាពខ្ពស់សម្រាប់ជួយបន្ធូរបន្ថយការប្រែប្រួលអាកាសធាតុ។ តែទោះជាយ៉ាងណាក៏ដោយ ការងារការពារព្រៃឈើមួយចំនួនបានទទួលបរាជ័យដោយសារ ខ្វះការយកចិត្តទុកដាក់លើតម្រូវការ ក្តីរំពឹងទុក ជំនាញ ចំណេះដឹង និងការចូលរួមរបស់ប្រជាសហគមន៍ ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តកិច្ចប្រឹងប្រែងការពារព្រៃឈើ។តំបន់ទំនាបទន្លេមេគង្គ គឺជាកន្លែងដែលប្រជាពលរដ្ឋរាប់ សិបលាននាក់ប្រកបមុខរបរចិញ្ចឹមជីវិតដោយពឹងផ្អែកទៅលើធនធានព្រៃឈើ ដូចនេះការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រនានាដើម្បីការពារព្រៃឈើ កាត់បន្ថយការសាយភាយជាតិកាបោន និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុមិនអាចទទួលជោគជ័យទេប្រសិនបើគ្មានការចូលរួមយ៉ាងសកម្មពីសហគមន៍មូលដ្ឋាន។

**ទិដ្ឋភាពរួម** កម្មវិធីសមធម៌និងពង្រឹងបណ្តាញនៅមូលដ្ឋាន ក្នុងតំបន់មេគង្គ(GREEN Mekong) ដែលផ្តល់មូលនិធិដោយ USAID ផ្តោតលើការកសាងសមត្ថភាពអ្នករៀបចំគោលនយោបាយ និងអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន នៅតំបន់ទំនាបទន្លេមេគង្គទាំងមូល ដើម្បីឲ្យពួកគេចូលរួមប្រកបដោយប្រសិទ្ធិភាពក្នុងដំណើរការពិភាក្សារបស់អ្នកពាក់ព័ន្ធស្តីពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ ទាំងនៅ ថ្នាក់ជាតិ និងថ្នាក់តំបន់ ដែលរួមចំណែកលើកកំពស់កិច្ចសហការ ការចែករំលែកព័ត៌មាន និងកសាងបណ្តាញការងារក្នុងតំបន់ទាំងមូល។

**គោលដៅ** GREEN Mekong មានគោលដៅពង្រឹង សមត្ថភាពអ្នករៀបចំគោលនយោបាយ និងអ្នក ពាក់ព័ន្ធនៅមូលដ្ឋាន ដើម្បីបញ្ជ្រាប និងលើកកម្ពស់សមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើទៅក្នុងដំណើរការរៀបចំកម្មវិធីស្ថាប័នថ្នាក់ជាតិ និងថ្នាក់តំបន់ ការសិក្សារៀនសូត្រ កិច្ចពិភាក្សាពីគោលនយោបាយ និងការអនុវត្តន៍ ជាក់ស្តែងនានា។សកម្មភាពនានា ត្រូវបានបង្កើតឡើងដើម្បីគាំទ្រគោលបំណងជាក់លាក់ទាំង ៣ ខាងក្រោម៖

- ពង្រឹងនូវគោលនយោបាយថ្នាក់ជាតិនិងថ្នាក់តំបន់ដោយគិតគូរអំពីកត្តាសមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ ។
- បង្កើនសមត្ថភាពរបស់អង្គការសង្គមស៊ីវិល (CSOs) ដើម្បីលើកកម្ពស់សមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ និង
- បង្កើនការយល់ដឹងដល់អ្នកពាក់ព័ន្ធ ស្តីអំពីសមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ។

**រយៈពេល** ៖កម្មវិធី GREEN Mekong មានកម្មវិធីរយៈពេល ៣ ឆ្នាំ (ចាប់ពីខែតុលា ឆ្នាំ ២០១២ រហូតដល់ខែ វិច្ឆិកា ឆ្នាំ ២០១៥) ។







**លទ្ធផលរំពឹងទុក របស់កម្មវិធីGREEN Mekong មានដូចខាងក្រោម៖**

- វេទិការៀនសូត្រអំពីគោលនយោបាយថ្នាក់ជាតិមួយ ដែលក្នុងនោះទស្សនទានរបស់អ្នកពាក់ព័ន្ធនៅមូលដ្ឋានទាក់ទងនឹងសមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើត្រូវបានធ្វើការពិភាក្សា ចែករំលែក និងយល់ដឹងដោយអ្នករៀបចំគោលនយោបាយនៅក្នុងប្រទេសនីមួយៗ យ៉ាងហោចណាស់ចំនួន ៣ ប្រទេស។
- យ៉ាងហោចណាស់មានអនុសាសន៍ស្តីពីគោលនយោបាយចំនួន២ ដើម្បីដោះស្រាយនូវបញ្ហានានាក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើដែលបានបង្កើតឡើង និងបានធ្វើទំនាក់ទំនងនៅក្នុងវេទិកានយោបាយនៅក្នុងសមាគមន៍ប្រជាជាតិអាស៊ីអា គ្នេយ៍ និងវេទិកាការងារជាលក្ខណៈបណ្តាញ។
- យ៉ាងហោចណាស់អង្គការសង្គមស៊ីវិលចំនួន ២០មកពីប្រទេសចំនួន ៤ ត្រូវបានបណ្តុះបណ្តាលស្តីពីសមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យព្រៃឈើនិងជួយសម្របសម្រួលដល់កិច្ចពិភាក្សារបស់អ្នកពាក់ព័ន្ធនៅមូលដ្ឋាន
- អង្ការសង្គមស៊ីវិលចំនួន ១០ មកពីបណ្តាប្រទេសយ៉ាងហោចណាស់ចំនួន៤ ត្រូវបានទទួលការគាំទ្រដោយផ្ទាល់ ដើម្បីប្រមូលផ្តុំ រៀបចំនូវទស្សនវិស័យរបស់អ្នកពាក់ព័ន្ធនៅមូលដ្ឋាន ស្តីអំពី ការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យព្រៃឈើដល់អ្នករៀបចំបង្កើតគោលនយោបាយនានាក្នុងស្ថានភាពភូមិសាស្ត្ររបស់ពួកគេ។
- យ៉ាងហោចណាស់មានមនុស្សចំនួន ១០,០០០នាក់អាចទទួលបាននូវព័ត៌មានយ៉ាងល្អអំពីសមធម៌ ស្តីអំពី ការកាត់បន្ថយការប្រែប្រួលអាកាសកាសនៅក្នុងវិស័យព្រៃឈើ។
- ការរួមបញ្ចូលកត្តាយេនឌ័រដើម្បីធ្វើឲ្យប្រសើរឡើងថែមទៀតនូវសមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ ។
- លើកកំពស់បណ្តាញកាងារថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីចែករំលែកនូវលទ្ធផលនៃការសិក្សា និងការអនុវត្តល្អ នានា ក្នុងការជំរុញអោយមាននូវសមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ។


កម្មវិធីGREEN Mekong
RECOFTC- មជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ
ប្រអប់សំបុត្រ P.O. 1111 ការិយាល័យប្រៃសណីយ៍ ក្បេតសាស្ត្រ
វិថី ផាហ៊ុនយោធិន ក្រុងបាងកក 10903 ប្រទេសថៃ
សូមទំនាក់ទំនងតាមទូរស័ព្ទលេខ
Tel: +66 (0)2 940 5700 ext 3242
Email: green.mekong@recoftc.org

រដ្ឋបាលព្រៃឈើ
#៤០ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល ២
ខ័ណ្ឌដូនពេញ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ ៖ +855 (0)23 214 651
ទូរសារ ៖ +855 (0)23 212 201
**Email:** cambodia@recoftc.org


សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅក្នុងគេហទំព័ររបស់យើង ៖http://www.recoftc.org/site/resources/GREEN-Mekong/